# ការរក្សាការពារ ក្នុងរឿងក្ដីរដ្ឋប្បវេណី ផ្នែក 1

ថ្ងៃទី 21 ខែកុម្ភៈ ឆ្នាំ2018

ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់
MAEDA Yuta

# ប្រភេទនៃការរក្សាការពារ
# ក្នុងរឿងក្តីរដ្ឋប្បវេណី

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

- ការរឹបអូសជាបណ្ដោះអាសន្ន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា531 ចំណុច ក.)

- ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ (មាត្រាដដែល ចំណុច ខ.)
  - ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់
  - ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង

- ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន (មាត្រាដដែល ចំណុច គ.)

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

ការរឹបអូសជាបណ្តោះអាសន្ន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា531 ចំណុច ក.)

- <u>សិទ្ធិដែលត្រូវបានរក្សាការពារគឺ សិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់</u>
- គោលបំណង គឺដើម្បីកុំឲ្យកូនបំណុលចាត់ចែងទ្រព្យសម្បត្តិ ហើយការធានានូវទ្រព្យសម្បត្តិទទួលខុសត្រូវរបស់កូនបំណុលសម្រាប់ការអនុវត្តដោយបង្ខំនៅពេលអនាគត។
- កម្មវត្ថុមានច្រើនប្រភេទ (ប្រភេទដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានដូចជា ចលនវត្ថុ (ច្បាប់ដដែល មាត្រា565), សិទ្ធិលើបំណុល និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត(ច្បាប់ដដែល មាត្រា566), អចលនវត្ថុ(ច្បាប់ដដែល មាត្រា567), នាវា(ច្បាប់ដដែល មាត្រា568))។

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា531 ចំណុច ខ.)

1. ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

- <u>**សិទ្ធិដែលត្រូវបានរក្សាការពារគឺ សិទ្ធិទាមទារឲ្យប្រគល់វត្ថុដែលបានកំណត់ជាក់លាក់**</u>
- គោលបំណងគឺ ហាមឃាត់កូនបំណុលកុំឲ្យផ្ទេរនូវការកាន់កាប់វត្ថុដែលបានកំណត់ជាក់លាក់ទៅឲ្យតតិយជន ហើយកំណត់អំពីភាគីម្ខាងទៀតនៃការទាមទារឲ្យប្រគល់។
- ខ្លឹមសារនៃការចាត់ចែងជាបណ្ដោះអាសន្នជាធម្មតាគឺ បង្គាប់ឲ្យយកកម្មវត្ថុមកឲ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រង (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា549 មាត្រា571 កថា.ទី1) ប៉ុន្តែ នៅប្រទេសជប៉ុន ភាគច្រើនតុលាការអនុញ្ញាតឲ្យកូនបំណុលប្រើប្រាស់កម្មវត្ថុ។ ផ្អែកតាមច្បាប់ ក៏អាចឲ្យយកកម្មវត្ថុមកឲ្យម្ចាស់បំណុលថែរក្សាគ្រប់គ្រងបានដែរ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា549)។

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា531 ចំណុច ខ.)

2. ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង

- **សិទ្ធិដែលត្រូវបានរក្សាការពារគឺ សិទ្ធិទាមទារឲ្យផ្តល់តាវកាលិកចំពោះវត្ថុដែលបានកំណត់ជាក់លាក់ (ស្ទើរតែគ្រប់ករណីគឺជា សិទ្ធិទាមទារឲ្យចុះបញ្ជី)**
- គោលបំណងគឺ ហាមឃាត់កូនបំណុលកុំឲ្យចាត់ចែង (ការផ្ទេរកម្មសិទ្ធិ ការបង្កើតហ៊ីប៉ូតែកជាដើម) នូវវត្ថុដែលបានកំណត់ជាក់លាក់ ហើយកំណត់ភាគីម្ខាងទៀតនៃការទាមទារ។

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា531 ចំណុច គ.)

- គោលបំណងគឺ ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា548 កថា.ទី2)

  ⇒ខុសពី ការរឹបអូសជាបណ្តោះអាសន្ន និង ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ហើយ**<u>មិនមែនមានគោលបំណងធ្វើការរក្សាការពារសម្រាប់ការអនុវត្តដោយបង្ខំនៅពេលអនាគតទេ</u>**។

- អាចមានពាក្យសុំរក្សាការពារច្រើនប្រភេទផ្សេងៗគ្នាចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ (ការហាមឃាត់ដំណើរការសាងសង់ជាបណ្តោះអាសន្ន ការបង់ប្រាក់ជាបណ្តោះអាសន្នជាដើម)។

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

- ការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី
  - ការរឹបអូសជាបណ្តោះអាសន្ន
  - ការចាត់ចែងជាបណ្តោះអាសន្ន
    - ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ
      - ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់
      - ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង
    - ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

ទស្សនៈទាក់ទងទៅនឹងប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្ន

តើជាពាក្យសុំដើម្បីធ្វើឲ្យសម្រេចបាននូវការអនុវត្តដោយបង្ខំនៅពេលអនាគតទេ ?

NO → *ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន*

YES ↓

តើសិទ្ធិដែលនឹងត្រូវបានរក្សាការពារគឺជាសិទ្ធិលើបំណុលដែលមានគោលបំណងឲ្យសងជាប្រាក់ទេ ?

NO → *ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ*

YES ↓

*ការរឹបអូសជាបណ្តោះអាសន្ន*

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

សំណួរ1៖ តើនៅក្នុងករណីសិក្សានេះ គួរតែដាក់ពាក្យសុំនៃការរក្សាការពារប្រភេទណាក្នុងរឿងក្តីរដ្ឋប្បវេណី?



ម្ចាស់បំណុលX

នៅថ្ងៃទី1 ខែមករា ឆ្នាំ2017 ខ្ញុំបានឲ្យកូនបំណុលYខ្ចីប្រាក់ 1 ម៉ឺនដុល្លារ ដោយកំណត់កាលបរិច្ឆេទសងត្រូវនឹងថ្ងៃទី31 ខែធ្នូ ឆ្នាំ 2017។ ប៉ុន្តែ Y មិនបានសង 1 ម៉ឺនដុល្លារទេ ទោះបីជាកាលបរិច្ឆេទសងបានកន្លងផុតក៏ដោយ។ លើសពីនេះទៀត ទ្រព្យសម្បត្តិរបស់ Y មានតែដីLប៉ុណ្ណោះ ហើយខ្ញុំបានឮថា Y ចង់លក់ដីL ឲ្យទៅមិត្តសំឡាញ់។ បើនៅតែបែបហ្នឹង ទោះបីជាខ្ញុំទទួលបានសាលក្រមឈ្នះក្តីចំពោះ Y ក៏ដោយ ក៏ប្រហែលជាមិនអាចអនុវត្តដោយបង្ខំបានទេ ដូច្នេះ ខ្ញុំនឹងដាក់ពាក្យសុំរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណីអំពី ដីL ទៅកាន់ Y។

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

សំណួរ1៖ តើនៅក្នុងករណីសិក្សានេះ គួរតែដាក់ពាក្យសុំនៃការរក្សាការពារប្រភេទណា ក្នុងរឿងក្ដីរដ្ឋប្បវេណី?

- គោលបំណងរបស់ X៖

  ការពារកុំឲ្យ Y ផ្ទេរកម្មសិទ្ធិលើដី L ឲ្យទៅតតិយជន ហើយធ្វើការអនុវត្តដោយបង្ខំ (ការលក់ដោយបង្ខំ) ចំពោះដី L នៅពេលអនាគត។

- សិទ្ធិដែលត្រូវបានរក្សាការពារ៖

  សិទ្ធិទាមទារឲ្យសងប្រាក់កម្ចីរបស់ X ចំពោះ Y

⇒ការរឹបអូសជាបណ្ដោះអាសន្ន

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

សំណួរ 2៖ តើនៅក្នុងករណីសិក្សានេះ គួរតែដាក់ពាក្យសុំប្រភេទណានៃការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី ?



ម្ចាស់បំណុលX

នៅថ្ងៃទី1 ខែមករា ឆ្នាំ2015 ខ្ញុំបានជួលបន្ទប់ R នៃ Apartment របស់ខ្ញុំឲ្យទៅកូនបំណុល Y ក្នុងថ្លៃឈ្នួល500ដុល្លារ ក្នុង1 ខែ ដោយមិនកំណត់រយៈពេលនៃការជួល។ ប៉ុន្តែ ចាប់ពីខែមករា ឆ្នាំ2017មក ដោយសារតែ Y មិនបានបង់ថ្លៃឈ្នួលផ្ទះមកឲ្យខ្ញុំសោះទោះបីជាបានដាស់តឿនច្រើនដងយ៉ាងណាក៏ដោយ ដូច្នេះ ខ្ញុំបានរំលាយកិច្ចសន្យាជួលនៅថ្ងៃទី1 ខែធ្នូ ឆ្នាំ2017។ ប៉ុន្តែ Y មិនទាន់បានចុះចេញ និង ប្រគល់បន្ទប់ R នោះមកឲ្យខ្ញុំនៅឡើយ។ បើនៅតែបែបហ្នឹង Y ប្រហែលជាឲ្យតតិយជនមកស្នាក់នៅក្នុងបន្ទប់ R ផងក៏មិនដឹង ហេតុនេះខ្ញុំនឹងដាក់ពាក្យសុំចាត់ចែងជាបណ្ដោះអាសន្នលើបន្ទប់ R។

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

សំណួរ 2៖ តើនៅក្នុងករណីសិក្សានេះ គួរតែដាក់ពាក្យសុំប្រភេទណានៃការរក្សាការពារក្នុង
រឿងក្ដីរដ្ឋប្បវេណី

- គោលបំណងរបស់ X ៖
  ការពារកុំឲ្យ Y ផ្ទេរការកាន់កាប់បន្ទប់ R ឲ្យទៅតតិយជន ហើយធ្វើការអនុវត្តដោយបង្ខំ (ការប្រគល់) ចំពោះបន្ទប់ R នៅពេលអនាគត។

- សិទ្ធិដែលត្រូវបានរក្សាការពារ ៖
  សិទ្ធិទាមទារឲ្យសងកម្មវត្ថុរបស់ X ត្រឡប់មកវិញ ដោយផ្អែកលើការបញ្ចប់ភតិសន្យាជាមួយ Y។

⇒ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

សំណួរ 3៖ តើនៅក្នុងករណីសិក្សានេះ គួរតែដាក់ពាក្យសុំនៃការរក្សាការពារ ប្រភេទណាក្នុងរឿងក្តីរដ្ឋប្បវេណី ?



ម្ចាស់បំណុលX

នៅថ្ងៃទី1 ខែមករា ឆ្នាំ2018 ខ្ញុំបានបុកជាមួយឡានដែលកូនបំណុលY បានបើក ហើយបណ្តាលឲ្យបាក់ជើងទាំងពីរ។ នៅពេលដែលខ្ញុំទៅពេទ្យ គ្រូពេទ្យបាននិយាយថា ត្រូវតែធ្វើការវះកាត់ ប៉ុន្តែ ដោយសារតែខ្ញុំក្រីក្រ ព្រមទាំងបាក់ជើងបែបនេះទៀត ក៏មិនអាចការងារធ្វើបានដែរ ដូច្នេះ បើត្រូវបង់ថ្លៃសម្រាប់ការវះកាត់ ខ្ញុំនឹងមិនអាចមានប្រាក់សម្រាប់ថ្លៃជីវភាពទេ ហេតុនេះ ខ្ញុំនឹងដាក់ពាក្យសុំចាត់ចែងជាបណ្តោះអាសន្នឲ្យY បង់ថ្លៃជីវភាពជាក់ស្តែងដែលកំពុងជួបប្រទះ។

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី

សំណួរ 3៖ តើនៅក្នុងករណីសិក្សានេះ គួរតែដាក់ពាក្យសុំប្រភេទណានៃការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី ?

- គោលបំណងរបស់ X ៖

ឲ្យ Y បង់ប្រាក់ថ្លៃជីវភាពជាក់ស្តែងដែលកំពុងជួបប្រទះ (1 ភាគនៃប្រាក់សំណងការខូចខាត) ជាមុន មុនពេលចេញសាលក្រមអង្គសេចក្តី ដើម្បីជៀសវាងនូវភាពខ្វះខាតខាងជីវភាព។

→ មិនមែនដើម្បីធ្វើឲ្យសម្រេចនូវការអនុវត្តដោយបង្ខំនៅពេលអនាគតទេ។

- សិទ្ធិដែលត្រូវបានរក្សាការពារ ៖

សិទ្ធិទាមទារសំណងនៃការខូចខាតរបស់X ចំពោះY ដោយផ្អែកតាមអំពើអនីត្យានុកូល

⇒ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន (ការបង់ប្រាក់ជាបណ្តោះអាសន្ន)